مدرسة اهل البيت
صلوات الله عليهم

# សាលា អាស់ហុល-បៃត៍

## សៀវភៅសិក្សា សីលធម៌ (أَخْلَاقٌ) ថ្នាក់ទី ៥

(អាយុ ៩-១០ ឆ្នាំ)

قَالَ النَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ الْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្ដាﷺមានព្រះវចនៈថាៈ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា

មេរៀនទី ១ សីលធម៌គឺអ្វី ?........ ៥
មេរៀនទី ២ ទស្សនៈអំពីបាប ........ ៧
មេរៀនទី ៣ ហ្វួរម៉ាត់ម៉ាស់យ៉ិដ្ឋ........ ៩
មេរៀនទី ៤ គោរពឪពុកម្ដាយ........ ១១
មេរៀនទី ៥ សេចក្ដីស្អាត........ ១៣
មេរៀនទី ៦ សេចក្ដីក្លាហាននិងសេចក្ដីកំសាក ........ ១៥
មេរៀនទី ៧ មេត្តាចិត្តនិងចិត្តស្លូត........១៧
មេរៀនទី ៨ ការប្រព្រឹត្តខ្លួននៅចំពោះមុខសាធារណៈជន ........ ១៨
មេរៀនទី ៩ បដិសណ្ឋារកិច្ច........២០
មេរៀនទី ១០ ជួយបណ្ដាអ្នកទន់ខ្សោយ........២១
មេរៀនទី ១១ សប្បុរសធម៌ ........២២
មេរៀនទី ១២ ចណ្ឌាភាព ឬ អាការកាចសាហាវ ........ ២៣
មេរៀនទី ១៣ សេចក្ដីទៀងត្រង់ ........២៤
មេរៀនទី ១៤ សេចក្ដីព្រហើន........២៦
មេរៀនទី ១៥ សេចក្ដីខ្ជិលប្រអូស ........ ២៧
មេរៀនទី ១៦ សេចក្ដីតក់ក្រហល់ ........២៩
មេរៀនទី ១៧ អំនួត ........ ៣១
មេរៀនទី ១៨ ការសងសឹក........៣៣

## មេរៀនទី ១

# សីលធម៌គឺអ្វី?

អាក់ឡាក់ (أَخْلَاقٌ) មានន័យថា សីលធម៌ ។ គឺមានចរិយាមារយាទល្អប្រពៃ ។ មានចរិយាមារយាទល្អជាប្រការសំខាន់ តែពិបាកណាស់ ។ ព្រះសាស្ដាមូហាំម៉ាដ់ ﷺមានព្រះវចនៈថា៖ "ខ្ញុំﷺត្រូវចាត់បញ្ជូនមកដើម្បីដុសខាត់ចរិយាមារយាទអស់លោកឲ្យសុក្រឹតឥតខ្ចោះ[1] ។" បានសេចក្ដីថាភារកិច្ចសំខាន់បំផុតមួយក្នុងចំណោមភារកិច្ចច្រើនដែលអល់ឡោះហ៍عز وجلដាក់មកលើព្រះសាស្ដាﷺនោះ គឺបង្ហាត់បង្រៀនយើងឲ្យមានសីលធម៌សុក្រឹតក្នុងខ្លួន ។

ទទួលបាននូវសីលធម៌ប្រសើរបំផុត ប្រៀបបាននឹងប្រវាឡើងពីក្នុងរូងជ្រៅ ។ ចូរអ្នកគិតមើលខ្លួនឯងកំពុងប្រវាឡើងពីក្នុងរណ្ដៅជ្រៅដូចផែនដី ។ នៅក្នុងរូងយើងមើលអ្វីមិនឃើញទេ ភ្នែកយើងពុំមានប្រយោជន៍ទេ ។ យើងត្រូវរកផ្លូវដោយប្រើដៃ ។ ពេលយើងឡើងខ្ពស់ទៅៗ យើងឃើញពន្លឺច្បាស់ឡើងៗ ភ្នែកយើងនឹងបើកធំឡើងៗ ។ ដូចគ្នាដែរ ពេលយើងព្យាយាមផ្លាស់ប្ដូរបុគ្គលលក្ខណៈយើងឲ្យប្រសើរឡើង យើងអនុវត្តិបន្តិចម្ដងៗ ឲ្យកាន់តែខ្ពស់ឡើងៗ ។ ដរាបណាយើងប្រវាឡើងទៅជិតពន្លឺអល់ឡោះហ៍عز وجل ដរាបនោះសីលធម៌យើងប្រសើរឡើង ។ លុះចេញផុតពីរូង យើងត្រូវពន្លឺចោមជុំ យើងអាចមើលឃើញឆ្ងាយពីកន្លែងរូងនោះ ។ យើងអាចមើលឃើញមេឃ ឃើញថ្ងៃ ។ ពេលយើងបានទៅដល់កំពូលបុគ្គលលក្ខណៈយើង វិញ្ញាណយើងត្រូវរស្មីអល់ឡោះហ៍عز وجلចោមជុំ វិញ្ញាណយើងអាចមើលឃើញក្នុងភាពងងឹត ក្នុងភាពងងឹតដែលគេចង់ទាក់ទាញយើងឲ្យចូល ។ ដូច្នេះវិញ្ញាណមើលឃើញផ្លូវទៅរកអល់ឡោះហ៍عز وجل ។ ពិបាកទៅដល់ថ្នាក់នេះណាស់ តែវាជាប៉ែកមួយនៃការពិសោធន៍ក្នុងលោកនេះ នេះជាមធ្យោបាយមួយគត់ដើម្បីទៅជាបក្សពួកពិតប្រាកដម្នាក់របស់ព្រះសាស្ដាﷺ ។

---

[1] . " بُعِثْتُ لأُتَمِّمَ حُسْنَ الأَخْلاَقِ " قَالَ وَحَدَّثَنِي عَنْ مَالِكٍ، أَنَّهُ قَدْ بَلَغَهُ أَنَّ رَسُولَ اللَّهِ صلى الله عليه وسلم (Yahya related to me from Malik that he had heard that the Messenger of Allah, may Allah bless him and grant him peace, said, "I was sent to perfect good character."), Muwatta Malik (موطأ مالك), Arabic reference: Book 47, Hadith 1643, USC-MSA web (English) reference: Book 47, Hadith 8

នៅក្នុងស៊ូរ៉ោះត៍ អាន់-នូរ អាយ៉ាស់ ៣៥ និង ៣៦ អល់ឡោះហ៍ﷻមានព្រះបន្ទូលថា៖

۞ٱللَّهُ نُورُ ٱلسَّمَٰوَٰتِ وَٱلْأَرْضِ ۚ مَثَلُ نُورِهِۦ كَمِشْكَوٰةٍ فِيهَا مِصْبَاحٌ ۖ ٱلْمِصْبَاحُ فِى زُجَاجَةٍ ۖ ٱلزُّجَاجَةُ كَأَنَّهَا كَوْكَبٌ
دُرِّىٌّ يُوقَدُ مِن شَجَرَةٍ مُّبَٰرَكَةٍ زَيْتُونَةٍ لَّا شَرْقِيَّةٍ وَلَا غَرْبِيَّةٍ يَكَادُ زَيْتُهَا يُضِىٓءُ وَلَوْ لَمْ تَمْسَسْهُ نَارٌ ۚ نُّورٌ عَلَىٰ نُورٍ ۗ
يَهْدِى ٱللَّهُ لِنُورِهِۦ مَن يَشَآءُ ۚ وَيَضْرِبُ ٱللَّهُ ٱلْأَمْثَٰلَ لِلنَّاسِ ۗ وَٱللَّهُ بِكُلِّ شَىْءٍ عَلِيمٌ ﴿٣٥﴾ فِى بُيُوتٍ أَذِنَ ٱللَّهُ أَن
تُرْفَعَ وَيُذْكَرَ فِيهَا ٱسْمُهُۥ يُسَبِّحُ لَهُۥ فِيهَا بِٱلْغُدُوِّ وَٱلْءَاصَالِ ﴿٣٦﴾

*៣៥. អល់ឡោះហ៍ជារស្មីនៃមេឃទាំងឡាយនិងផែនដី ។ រស្មីនៃព្រះអង្គប្រៀបបាននឹងអង្កែលុង (ហ៊ឹងដែលលុងក្នុងជញ្ជាំង) ដែលមានចង្កៀងមួយ[ភ្លឺ]នៅក្នុងនោះ ។ ចង្កៀងនោះនៅក្នុងកែវផលិក (កែវវិសេសមួយប្រភេទមានពន្លឺភ្លឺថាំងរស្មីផ្លេកៗ) ។ កែវនោះ[ថ្លាណាស់ វាភ្លឺចែងចាំង]ហាក់ដូចផ្កាយដែលមានពន្លឺត្រចះត្រចង់ ឆេះឡើងអាស្រ័យ[ប្រេងឥន្ធនៈនៃ]ដើមឈើប្រកបដោយពរជ័យសិរីសួស្តី ដើមស៊ៃទូនដែលមិនមកពីទិសខាងកើតទេ មិនមកពីទិសខាងលិចទេ ប្រេងរបស់វា[មានរស្មីភ្លឺត្រចះត្រចង់ណាស់ វា]ស្ទើរតែចែងចាំងរស្មីដោយពុំបាច់មានភ្លើងប៉ះពាល់វាទេ ។ រស្មីលើរស្មី ។ អល់ឡោះហ៍ទ្រង់ដឹកនាំអ្នកណាមួយឆ្ពោះទៅរករស្មីនៃព្រះអង្គស្រេចតែលើព្រះអង្គ ។ អល់ឡោះហ៍លើកឡើងនូវឧទាហរណ៍ផ្សេងៗសម្រាប់មនុស្សទាំងឡាយ ។ អល់ឡោះហ៍ទ្រង់ញាណសព្វសារពើ ។ ៣៦. [រស្មីនេះភ្លឺត្រចះត្រចង់នៅ]ក្នុងបណ្តាគេហដ្ឋានដែលអល់ឡោះហ៍អនុញ្ញាតឲ្យលើកតម្កើង នៅក្នុងបណ្តាគេហដ្ឋាននោះគេថ្លែងព្រះនាមព្រះអង្គ ។ ថ្វាយថោមនាការចំពោះព្រះអង្គនាទីនោះទាំងព្រឹកទាំងល្ងាច ។* (២៤:៣៥-៣៦)

មានរស្មីសម្រាប់បង្ហាញផ្លូវយើងក្នុងភាពងងឹត ។ អល់ឡោះហ៍ﷻប្រាប់យើងថាព្រះអង្គﷻនឹងបង្ហាញផ្លូវយើងដោយរស្មីព្រះអង្គﷻ ព្រះអង្គﷻនឹងជួយយើងឲ្យឡើងពីក្នុងរូង ។

តើយើងអាចប្តូរសីលធម៌យើងឲ្យកាន់តែប្រសើរឡើងបានដូចម្តេច? យើងអាចដូរសីលធម៌យើងឲ្យកាន់តែប្រសើរឡើងបាន ដោយព្យាយាមធ្វើល្អគ្រប់ពេលកុំដាច់ ទោះបីនៅឯផ្ទះក្តី នៅឯម៉ាស់យ៊ិដក្តី នៅឯសាលារៀនក្តី ឬនៅជាមួយមិត្តយើងក្តី ។ រាល់ពេលដែលយើងធ្វើអាក្រក់ យើងត្រូវសូមទោសអល់ឡោះហ៍ﷻ ។ យើងត្រូវខិតខំដែរកុំឲ្យធ្វើកំហុសដដែលម្តងទៀត ។

# មេរៀនទី ២

## ទស្សនៈអំពីបាប

បាបគឺការប្រព្រឹត្តិរបស់បុគ្គលដែលធ្វើទង្វើអាក្រក់ ។ ចូរអ្នកគិតថាអ្វីៗដែលអ្នកធ្វើសុទ្ធតែត្រូវអល់ឡោះហ្ទ័عز وجلឲ្យពិន្ទុ ។ បើអ្នកធ្វើទង្វើល្អ អ្នកនឹងបានបុណ្យ (ស្វាវ៉ាប់) បើអ្នកធ្វើទង្វើអាក្រក់ អ្នកនឹងបានបាប ។

ថ្ងៃជំនុំជម្រះអល់ឡោះហ្ទ័عز وجلនឹងបង្ហាញពិន្ទុដែលអ្នកទទួលបាន ។ បើអ្នកបានបុណ្យ (ស្វាវ៉ាប់) ច្រើនជាង អ្នកនឹងបានចូលឋានសួគ៌ បើអ្នកបានបាបច្រើនជាងអ្នកនឹងចូលឋាននរក ។ មានតែបុគ្គលដែលមានបាបច្រើនជាងបុណ្យទេដែលនឹងចូលឋាននរក ។

អល់ឡោះហ្ទ័عز وجلមានព្រះបន្ទូលថា បាបមួយណាក៏ដោយដែលអ្នកធ្វើ តូចក្តី ធំក្តី ដោយឲ្យគេឃើញក្តី ដោយលាក់បាំងក្តី ព្រះអង្គعز وجلដឹងទាំងអស់ ។ ព្រះអង្គعز وجلមានព្រះបន្ទូលដែរថាព្រះអង្គعز وجلនឹងលើកទោសឲ្យអ្នកណាដែលតៅបាស្ទ៉ (គឺស្តាយក្រោយ) មិនធ្វើបាបដដែលទៀតទេ ។

បុរសពីរនាក់មករកអ៊ីម៉ាំទី ៦ របស់យើងصلوات الله عليه والسلام ទូលព្រះអង្គصلوات الله عليه والسلامថាពួកគេចង់តៅបាស្ទ៉ដែលបានសាងបាប ។ បុរសទី ១ ថាគាត់បានសាងបាបតូចច្រើន បុរសទី ២ ថាគាត់បានសាងបាបធំពីរ ។ អ៊ីម៉ាំصلوات الله عليه والسلامបានប្រាប់បុរសទី ១ ឲ្យរើសថ្មមួយដុំសម្រាប់បាបតូចមួយដែលគាត់បានធ្វើ ។ ព្រះអង្គصلوات الله عليه والسلامប្រាប់បុរសទី ២ ឲ្យគាត់យកដុំថ្មធំពីរសម្រាប់បាបធំទាំងពីរ ។ ក្រោយមកបន្តិច បុរសទាំងពីរត្រឡប់មកវិញ សួរអ៊ីម៉ាំصلوات الله عليه والسلامថាពួកគាត់ត្រូវធ្វើអ្វីបន្ទាប់ពីនោះ ។ អ៊ីម៉ាំصلوات الله عليه والسلامប្រាប់បុរសទាំងពីរឲ្យយកដុំថ្មត្រឡប់ទៅដាក់កន្លែងដើមរបស់វាវិញ កុំឲ្យខុសកន្លែង ។ បុរសដែលបានយកដុំថ្មធំពីរពិបាកលើកដុំថ្មធំៗនោះទៅដាក់កន្លែងដើមរបស់វាវិញណាស់ តែគាត់អាចធ្វើបានសម្រេច ។ បុរសដែលមានដុំថ្មច្រើនមិនដឹងនឹងយកដុំថ្មទៅដាក់កន្លែងណាទេ ព្រោះគាត់មានដុំថ្មច្រើន ចាំមិនបានទេថាគាត់បានរើសដុំថ្មមកពីកន្លែងណា ។

ឧត្តមគតិរឿងនេះគឺ ពិបាកតៅបាស្ទ៉បាបតូចៗណាស់ដែលបានធ្វើជាញឹកញយ ។

សំខាន់បំផុតឲ្យតៅបាស្ទ់ជានិច្ចកុំដាច់ សូមឲ្យអល់ឡោះហ្ទ៍عزّ وجلّលើកទោសឲ្យយើងដែលបានសាងបាប ព្រោះព្រះអង្គعزّ وجلّទ្រង់មហាសន្តោស មហាមេត្តាប្រណី ។

អ្នកដឹងទេថាបាបណាមួយដែលគេធ្វើជាញឹកញយ ?

## មេរៀនទី ៣

# ហ្រ៊ូរម៉ាត់ម៉ាស់ឃ្ជ៊ិដ្វ

ហ្រ៊ូរម៉ាត់ (حُرْمَت) មានន័យថាសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ ។ ពេលយើងទៅកាន់ម៉ាស់ឃ្ជ៊ិដ្វ ឬ អ៊ីមុំាបារ៉ យើងត្រូវដឹងថាយើងទៅដើម្បីនឹកដល់អល់ឡោះហ្វ៌ﷻ ។

ម៉ាស់ឃ្ជ៊ិដ្វនិងអ៊ីមុំាបារ៉មិនដូចគ្នាទេ ។ គេស្ម៌ឡាត្ញ៉នៅក្នុងម៉ាស់ឃ្ជ៊ិដ្វ ។

គេអាចប្រើអ៊ីមុំាបារ៉ជាកន្លែងធ្វើកិច្ចការផ្សេងៗបាន ដូចជាប្រជុំគ្នា បរិភោគ ស្ម៌ឡាត្ញ៉ ធ្វើឃុត្បាស៉្ញ ជាដើម ។ បានសេចក្ដីថាអ្នកអាចធ្វើប្រការនីមួយបាននៅក្នុងអ៊ីមុំាបារ៉ តែមិនអាចធ្វើប្រការនោះបានទេនៅក្នុងម៉ាស់ឃ្ជ៊ិដ្វ ។

នៅក្នុងម៉ាស់ឃ្ជ៊ិដ្វ អ្នកត្រូវរក្សាការស្ងៀមស្ងាត់ ។ និយាយព្រមនឹងពេលគេស្ម៌ឡាត្ញ៉ជាការប្រមាថមើលងាយ ។ បើអ្នកចាំបាច់ត្រូវនិយាយ ចូរកុំនិយាយអំពីប្រការមិនសំខាន់ជាដាច់ខាត ។

នៅក្នុងម៉ាស់ឃ្ជ៊ិដ្វក៏ដូចនៅក្នុងអ៊ីមុំាបារ៉ដែរ ចិត្តអ្នកត្រូវផ្ដោតទៅរកព្រះអ្នកបង្កើតអ្នក ។

នៅក្នុងអ៊ីមុំាបារ៉អនុញ្ញាតឲ្យនិយាយគ្នាបាន តែក្នុងពេលនីមួយប៉ុណ្ណោះ ។ បើគេដាក់តែឬដាក់បាយឲ្យបរិភោគ អ្នកអាចនិយាយគ្នាបាន តែពេលគេថ្លែងសុន្ទរកថាឬសូត្រឌូអ៊ារ្អ៉ អ្នកត្រូវស្ងាត់មាត់ អង្គុយស្ងៀមមួយកន្លែង មិនធ្វើកាយវិការ មិនរំខានគេ ។

បើអ្នកឃើញអ្នកណាម្នាក់ធ្វើឲ្យម៉ាស់ឃ្ជ៊ិដ្វណាឃ៊ិស វ៉ាឃ៊ិបលើអ្នកឲ្យប្រាប់អ្នកនោះឲ្យឈប់ធ្វើឲ្យម៉ាស់ឃ្ជ៊ិដ្វណាឃ៊ិស ។ វ៉ាឃ៊ិបឲ្យសំអាតម៉ាស់ឃ្ជ៊ិដ្វនិងធ្វើឲ្យម៉ាស់ឃ្ជ៊ិដ្វត្ហ៊ប្ហៀរដែរ ។

អ្នកមិនត្រូវរត់ មិនត្រូវលេងនៅក្នុងម៉ាស់ឃ្ជ៊ិដ្វឬនៅក្នុងអ៊ីមុំាបារ៉ជាដាច់ខាត ។

អ្នកត្រូវប្រព្រឹត្តខ្លួននៅក្នុងម៉ាស់ឃ្ជ៊ិដ្វ ហាក់ដូចជាម៉ាស់ឃ្ជ៊ិដ្វនោះជារបស់អល់ឡោះហ្វ៌ﷻ ។ ទោះបីយើងដឹងថាអល់ឡោះហ្វ៌ﷻមិនត្រូវការលំនៅក៏ដោយ តែយើងត្រូវធ្វើដូចជាព្រះអង្គﷻមើលយើង យើងត្រូវតែនៅក្បែរព្រះអង្គﷻ ។

## ម៉ាស់យិដ្ជាកន្លែងដែលយើងចូលទៅជិតអល់ឡោះហ្ ﷻបំផុតដោយចិត្ត

ពេលចូលទៅក្នុងម៉ាស់យ៉ិដ្ យើងត្រូវថា៖

"ក្នុងព្រះនាមអល់ឡោះហ្ ﷻ ខ្ញុំទុកចិត្តលើអល់ឡោះហ្ ﷻ ពុំមានឥទ្ធិពលក្រៅពីអល់ឡោះហ្ ﷻទេ (بِسْمِ اللهِ، تَوَكَّلْتُ عَلَى اللهِ وَلا حَوْلَ وَلا قُوَّةَ إِلاّ بِالله) ។ ពេលចេញពីម៉ាស់យ៉ិដ្ យើងត្រូវសូត្រថា៖

"ក្នុងព្រះនាមអល់ឡោះហ្ ﷻ សូមអល់ឡោះហ្ ﷻការពារខ្ញុំពីស្ហៃតូនត្រូវបណ្ដាសា (بِسْمِ اللهِ، أَعُوذُ بِاللَّهِ مِنَ الشَّيْطَانِ الرَّجِيمِ)"

ហេតុអ្វីយើងត្រូវស្ងៀមស្ងាត់មិននិយាយគ្នានៅក្នុងម៉ាស់យ៉ិដ្ ?

មូលហេតុដែលយើងត្រូវស្ងៀមស្ងាត់មិននិយាយគ្នានៅក្នុងម៉ាស់យ៉ិដនោះ គឺដើម្បីគេអាចសិក្សានិងយល់សាសនាអ៊ីស្លាមបានប្រសើរឡើង ។ បានសេចក្ដីថាបើគេសួរយើងដោយសំណួរណាមួយ យើងអាចជួយគេបានដោយឆ្លើយតបគេដូច្នេះយើងធ្វើឲ្យអល់ឡោះហ្ ﷻពេញចិត្ត ។

យើងអាចប្រព្រឹត្តខ្លួនជាគំរូល្អសម្រាប់អ្នកដទៃបានដែរ ដូច្នេះអល់ឡោះហ្ ﷻនឹងប្រទានរង្វាន់ (ស្វាប់) ឲ្យយើង ។

អាយ៉ាទុលឡោះហ្ ឃូមៃនី មានប្រសាសន៍ថា៖ "អ្នកបង្ហាញផ្លូវល្អមានតម្លៃស្មើអ្នកធ្វើល្អដែរ ។" បានសេចក្ដីថាពេលអ្នកប្រាប់គេឲ្យធ្វើល្អនិងមានសប្បុរសធម៌ដូចម្ដេចនោះ អ្នកនឹងបានរង្វាន់ (ស្វាប់) ស្មើអ្នកដែលអនុវត្តិការធ្វើទង្វើល្អនិងការមានចិត្តសប្បុរសដែរ ។

ពេលគេធ្វើសុន្ទរកថាឬឌូអាអ៊ុំជាភាសាដែលគេមិនយល់ យើងត្រូវស្ងៀមស្ងាត់មិននិយាយគ្នាទេ ដើម្បីនឹងមិនរំខានអ្នកដែលស្ដាប់ ។

ដើម្បីបញ្ចប់ យើងត្រូវរក្សាការស្ងៀមស្ងាត់គ្រប់ទីកន្លែងណាដែលគេលើកតម្កើងអល់ឡោះហ្ ﷻឬថាព្រះនាមអល់ឡោះហ្ ﷻ ។ ធ្វើដូច្នេះសឲ្យឃើញថាយើងសម្ដែងសេចក្ដីគោរពចំពោះព្រះអ្នកបង្កើតយើង ។

## មេរៀនទី ៤

# គោរពឪពុកម្ដាយ

គោរពមានន័យថាស្ដាប់គេ ឲ្យតម្លៃគេ ។ មានន័យដែរថាគិតថាគេជាបុគ្គលសំខាន់ យកចិត្តទុកដាក់នឹងគេដោយមិនធ្វើមុខក្រញូវឬមិនពេញចិត្ត ។

អល់ឡោះហ៊ូ عزوجل មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន (២:៨៣) ថាឲ្យធ្វើតាមបង្គាប់ព្រះអង្គ عزوجل និងគោរពឪពុកម្ដាយយើង ។ សឲ្យឃើញថាស្ដាប់ និងធ្វើតាមបង្គាប់ឪពុកម្ដាយជាប្រការសំខាន់ណាស់ ។ ហាឌីស្ហមួយចែងថា "ឋានសួគ៌នៅក្រោមជើងម្ដាយអ្នក[2] ។" បានសេចក្ដីថា អ្នកណាធ្វើឲ្យម្ដាយសប្បាយចិត្ត ធ្វើឲ្យម្ដាយពេញចិត្តខ្លួន អ្នកនោះនឹងមិនពិបាកចូលឋានសួគ៌ទេ ។ ព្រះសាស្ដាយើង ﷺ មានព្រះវចនៈថា៖ "គេមិនទទួលយកទេ ស៊ិឡាត៌ (عبادة) របស់បុគ្គលណា ដែលធ្វើឲ្យឪពុកម្ដាយទាស់ចិត្តនោះ ។"



ហាឌីស្ហនេះបញ្ជាក់ប្រាប់យើងថា អល់ឡោះហ៊ូ عزوجل នឹងមិនទទួលយកស៊ិឡាត៌របស់បុគ្គលណាដែលធ្វើឲ្យឪពុកម្ដាយទាស់ចិត្ត ។ ព្រះបញ្ជាសំខាន់បំផុតរបស់អល់ឡោះហ៊ូ عزوجل គឺស្ដាប់បង្គាប់ឪពុកម្ដាយ ហេតុដូច្នេះ តើយើងអាចប្រឆាំងប្រការនេះបានដូចម្ដេច ?

កូនៗដែលបានធំនៅក្នុងសង្គមប្រទេសខាងលិច មិនឃើញគេគោរពឪពុកម្ដាយខ្លួនទេ នៅជុំវិញខ្លួននោះ ។ រៀបការរួច គេចាកចោលឪពុកម្ដាយខ្លួនជាធម្មតា

---

[2] source: https://sunnah.com/nasai:3104. Reference : Sunan an-Nasa'i 3104. English translation : Vol. 1, Book 25, Hadith 3106 )

أَخْبَرَنَا عَبْدُ الْوَهَّابِ بْنُ عَبْدِ الْحَكَمِ الْوَرَّاقُ، قَالَ حَدَّثَنَا حَجَّاجٌ، عَنِ ابْنِ جُرَيْجٍ، قَالَ أَخْبَرَنِي مُحَمَّدُ بْنُ طَلْحَةَ، - وَهُوَ ابْنُ عَبْدِ اللَّهِ بْنِ عَبْدِ الرَّحْمَنِ - عَنْ أَبِيهِ طَلْحَةَ عَنْ مُعَاوِيَةَ بْنِ جَاهِمَةَ السُّلَمِيِّ، أَنَّ جَاهِمَةَ، جَاءَ إِلَى النَّبِيِّ صلى الله عليه وسلم فَقَالَ يَا رَسُولَ اللَّهِ أَرَدْتُ أَنْ أَغْزُوَ وَقَدْ جِئْتُ أَسْتَشِيرُكَ . فَقَالَ " هَلْ لَكَ مِنْ أُمٍّ " . قَالَ نَعَمْ . قَالَ " **فَالْزَمْهَا فَإِنَّ الْجَنَّةَ تَحْتَ رِجْلَيْهَا** " .

ដោយឲ្យឪពុកម្ដាយទៅរស់នៅឯគ្រឹះស្ថានសម្រាប់មនុស្សចាស់ ។

សាសនាអ៊ីស្លាមចែងប្រាប់យើងថាមិនត្រូវធ្វើបែបនេះទេ ។ គេត្រូវជួយឪពុកម្ដាយជានិច្ច មិនត្រូវបណ្ដោយឲ្យឪពុកម្ដាយរងការលំបាកឬបញ្ហាជាដាច់ខាត ។

ពេលក្រោកពីដេក ប្រការដំបូងបង្អស់ដែលអ្នកត្រូវធ្វើគឺទៅឲ្យសាឡាមឪពុកម្ដាយអ្នកថា៖ "អាស់-សាឡាមុ អ៊ាឡៃគុម" ។

កាតព្វកិច្ចត្រូវធ្វើចំពោះឪពុកម្ដាយគឺ៖

១. មិនត្រូវប្រើសម្ដីធំដាក់ឪពុកម្ដាយទេ ។

២. ពេលឪពុកម្ដាយចូលមកក្នុងបន្ទប់គ្រាដំបូង ចូរអ្នកក្រោកឈរបើអ្នកកំពុងអង្គុយ ។

៣. ចូរកុំនិយាយកាត់ឪពុកម្ដាយពេលឪពុកម្ដាយកំពុងនិយាយ ។

៤. ចូរកុំកែកំហុសឪពុកម្ដាយនៅពីមុខអ្នកដទៃ ។

អល់ឡោះហ្ ﷻ ស្រឡាញ់អ្នកដែលគោរពឪពុកម្ដាយណាស់ ព្រះអង្គ ﷻ ប្រទានរង្វាន់ (ស្ញាវ៉ាប់) ឲ្យអ្នកនោះ ។ អាយ៉ាទុលឡោះហ្ ឃុមៃនីមានប្រសាសន៍ថា៖ "មើលមុខម្ដាយនិងឪពុកខ្លួនដោយសេចក្ដីគោរព ប្រៀបបាននឹងមើលកាក់បាស់ គឺបានរង្វាន់ស្មើគ្នា ។"

**មេរៀនទី ៥**

# សេចក្តីស្អាត

រក្សាសេចក្តីស្អាតជាប្រការសំខាន់ណាស់ ។ បើអ្នកមិនសម្អាតខ្លួនទេ ទីបំផុតបណ្តាមេរោគនឹងកកើតលើខ្លួនអ្នកយ៉ាងងាយបំផុត បណ្តាលឲ្យអ្នកមានជម្ងឺ ។ អ្នកដទៃនឹងមើលមកអ្នកឃើញថាអ្នកអាក្រក់ ហើយចៀសឆ្ងាយពីអ្នក ។ អ្នកនឹងមិនស្រស់ស្រាយ មិនរវៀសរវៃទេ តែអ្នកនឹងបាក់ទឹកចិត្តនិងយឺតយ៉ាវ ។

ពេលអ្នកងូតទឹកសម្អាតខ្លួន ស្លៀកពាក់ សិតសក់ អ្នកនឹងមានអារម្មណ៍ស្រស់ស្រាយនិងស្រួលខ្លួន ។

ចូរព្យាយាមសម្អាតខ្លួនគ្រប់ពេល តែចូរយកចិត្តទុកដាក់លើសពីនេះពេលអ្នកចូលបង្គន់ ពេលអ្នកបរិភោគនិងពេលអ្នករៀបខ្លួនស្ឋ៌ឡាត់ ។



តើអ្នកត្រូវរក្សាសេចក្តីស្អាតដូចម្តេច ?

ពេលអ្នកបន្ទោបង់ អ្នកត្រូវលាងដោយទឹក ។ បើអ្នកប្រើក្រដាសតែម្យ៉ាង អ្នកនឹងណាយ៉ិស (មិនស្អាត) ។ បានសេចក្តីថា អ្នកមិនអាចប៉ះព្រះគម្ពីរគួរអានបានទេ មិនអាចស្ឋ៌ឡាត់បានទេ ។

ពេលចេញពីបង្គន់វិញ អ្នកត្រូវតែធ្វើឲ្យបង្គន់នោះស្អាតដដែល ឬស្អាតជាងមុនពេលអ្នកចូលមកបន្ទោបង់ ។ អ្នកត្រូវតែលាងដៃឲ្យស្អាតដែរ ដើម្បីនឹងឲ្យអ្នកជ្រះស្អាតពីបណ្តាមេរោគដែលអាចចម្លងមកអ្នក និងដើម្បីនឹងកុំឲ្យអ្នកចម្លងមេរោគទាំងនោះទៅលើចំណីឬកន្លែងផ្សេងទៀត ។

នៅផ្ទះ អ្នកត្រូវតែសម្អាតខ្លួនដោយដុសធ្មេញពេលព្រឹកនិងពេលយប់ ដោយលាងមុខពេលអ្នកក្រោកពីដេក និងងូតទឹកឲ្យទៀងទាត់ ។

អ៊ីមុាំទី ៨ របស់យើង ﷺ មានវចនៈថា៖ "រក្សាសេចក្តីបរិសុទ្ធនិងសេចក្តីស្អាតជាប៉ែកមួយនៃទម្លាប់របស់បណ្តាព្រះសាស្តា ។"

មុនអ្នកបរិភោគ ចូរលាងដៃដើម្បីកុំវាកខ្វក់ពេលអ្នកបរិភោគ ។ គេថាយកល្អ

ឲ្យដៃអ្នកសើមបន្តិចពេលអ្នកបរិភោគ ។ បើដៃអ្នកកខ្វក់ អ្នកអាចលេបមេរោគជាមួយចំណីបាន ។ វាអាចមិនល្អសម្រាប់អ្នកព្រោះអ្នកមិនដឹងទេថាអ្នកបានប៉ះពាល់អ្វីពេញមួយថ្ងៃនោះ ។

អល់ឡោះហ៊្ជាមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ (២:២២២) ថា៖

إِنَّ ٱللَّهَ يُحِبُّ ٱلتَّوَّٰبِينَ وَيُحِبُّ ٱلْمُتَطَهِّرِينَ ﴿٢٢٢﴾

*២២២. ... អល់ឡោះហ្ជាសព្វព្រះហឫទ័យអ្នកស្តាយក្រោយរាងចាលសារភាពកំហុស ព្រះអង្គសព្វព្រះហឫទ័យបណ្តាអ្នកជម្រះបន្សុទ្ធខ្លួន (២:២២២)*

អ្នកមិនត្រឹមតែត្រូវរក្សាសេចក្តីស្អាតគ្រប់ពេលប៉ុណ្ណោះទេ អ្នកត្រូវបោសសម្អាតអ្វីៗដែលនៅជុំវិញខ្លួនអ្នកដែរ ។ អ្នកត្រូវបោសម្អាតបន្ទប់ដេករបស់អ្នកព្យាយាមលាងចានអ្នក ។ បើអ្នកឃើញមានភាពរាត់រាយនៅជុំវិញខ្លួនអ្នក អ្នកត្រូវសាករៀបនិងបោសសម្អាតឲ្យមានរបៀប ទោះបីអ្នកដែលធ្វើឲ្យរាត់រាយនោះមិនមែនខ្លួនអ្នកក៏ដោយ ។ នេះជាប្រការសំខាន់នៅក្នុងកន្លែងសាធារណៈដូចជាម៉ាស់យ៊ិដ្ទនិងសាលារៀនជាដើម ។ បើទាំងអស់គ្នារើសសម្រាម ឬទាំងអស់គ្នាបោសសម្អាត ទីកន្លែងនឹងស្អាតនិងមានរបៀបរៀបរយ ជាផលប្រយោជន៍សម្រាប់ទាំងអស់គ្នា ។

ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺមានព្រះវចនៈថា៖ **"សេចក្តីស្អាតនិងសេចក្តីបរិសុទ្ធជាប៉ែកមួយនៃជំនឿ[3] ។"**

[3] Source: https://sunnah.com/muslim:223. Sahih Muslim, USC-MSA web (English) reference : Book 2, Hadith 432.

حَدَّثَنَا إِسْحَاقُ بْنُ مَنْصُورٍ، حَدَّثَنَا حَبَّانُ بْنُ هِلاَلٍ، حَدَّثَنَا أَبَانٌ، حَدَّثَنَا يَحْيَى، أَنَّ زَيْدًا، حَدَّثَهُ أَنَّ أَبَا سَلاَّمٍ حَدَّثَهُ عَنْ أَبِي مَالِكٍ الأَشْعَرِيِّ، قَالَ قَالَ رَسُولُ اللَّهِ صلى الله عليه وسلم " الطُّهُورُ شَطْرُ الإِيمَانِ وَالْحَمْدُ لِلَّهِ تَمْلأُ الْمِيزَانَ . وَسُبْحَانَ اللَّهِ وَالْحَمْدُ لِلَّهِ تَمْلآنِ - أَوْ تَمْلأُ - مَا بَيْنَ السَّمَوَاتِ وَالأَرْضِ وَالصَّلاَةُ نُورٌ وَالصَّدَقَةُ بُرْهَانٌ وَالصَّبْرُ ضِيَاءٌ وَالْقُرْآنُ حُجَّةٌ لَكَ أَوْ عَلَيْكَ كُلُّ النَّاسِ يَغْدُو فَبَائِعٌ نَفْسَهُ فَمُعْتِقُهَا أَوْ مُوبِقُهَا " .

## មេរៀនទី ៦

# សេចក្តីក្លាហាននិងសេចក្តីកំសាក

សេចក្តីក្លាហានគឺមានសមត្ថភាពពុះពារឧបសគ្គនានាដោយមិនគេចវេះ ឬរើសយកមធ្យោបាយងាយស្រួល ។ វេរចនៈរបស់សេចក្តីក្លាហានគឺសេចក្តីអង់អាច ។

សេចក្តីក្លាហានមិនមាននៅតែក្នុងសមរភូមិឬនៅក្នុងខ្សែភាពយន្តទេ តែសេចក្តីក្លាហានមាននៅក្នុងជីវិតរស់នៅរៀងរាល់ថ្ងៃដែរ ។ ឧទាហរណ៍ "ការពារជំនឿរបស់ខ្លួន" ក៏ជាសេចក្តីក្លាហានដែរ ។ បើអ្នកនៅសាលារៀន គេឲ្យអ្វីដែលហារ៉ាំមកអ្នក អ្នកត្រូវថា "ទេ អរគុណ ។ ខ្ញុំកាន់សាសនាអ៊ីស្លាម សាសនាខ្ញុំហាម" ។ មិនបានសេចក្តីថាអ្នកត្រូវវាយតប់បុគ្គលណាដែលឲ្យអ្វីមួយមកអ្នកនោះទេ ។ អ្នកត្រូវបដិសេធដោយវិធីគួរសម ហើយពន្យល់គេឲ្យដឹងមូលហេតុ ។

ផ្ទុយពីសេចក្តីក្លាហានគឺសេចក្តីកំសាក ពោលគឺ សម្តែងឲ្យអ្នកដទៃឃើញថាខ្លួនទន់ជ្រាយ ។ បើគេឲ្យរបស់ហារ៉ាំមកអ្នក អ្នកព្រមទទួលយកដើម្បីផ្គាប់ចិត្តគេ អ្នកសម្តែងឲ្យឃើញនូវសេចក្តីកំសាក មិនអនុញ្ញាតឲ្យធ្វើបែបនេះទេ ។ អ្នកត្រូវតែបដិសេធ តែដោយឆ្លើយតបដោយសេចក្តីគួរសម ។

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "សេចក្តីកំណាញ់ឬសេចក្តីកំសាកមិនល្អទេសម្រាប់អ្នកមានសទ្ធា[4] ។"

មូលហេតុដែលអ្នកកំសាក ព្រោះតែអ្នកខ្លាចអ្នកដទៃ ឬខ្លាចអ្វីដែលអ្នកដទៃអាចគិតអំពីខ្លួនអ្នក ។

បើអ្នកជឿអល់ឡោះហ៍عزّ وجلّ ហេតុអ្វីអ្នកត្រូវខ្លាចអ្នកដទៃ ? អល់ឡោះហ៍عزّ وجلّនឹងជួយអ្នក ។

អ្នកត្រូវតែធ្វើអ្វីដែលត្រឹមត្រូវ ទោះបីអ្នកដទៃប្រឆាំងអ្នកក៏ដោយ អល់ឡោះហ៍

---

[4] Source: https://sunnah.com/nasai:3104, Reference : Sunan Abi Dawud, English translation : Book 14, Hadith 2505.
حَدَّثَنَا عَبْدُ اللَّهِ بْنُ الْجَرَّاحِ، عَنْ عَبْدِ اللَّهِ بْنِ يَزِيدَ، عَنْ مُوسَى بْنِ عُلَىِّ بْنِ رَبَاحٍ، عَنْ أَبِيهِ، عَنْ عَبْدِ الْعَزِيزِ بْنِ مَرْوَانَ، قَالَ سَمِعْتُ أَبَا هُرَيْرَةَ، يَقُولُ سَمِعْتُ رَسُولَ اللَّهِ صلى الله عليه وسلم يَقُولُ : " شَرُّ مَا فِي رَجُلٍ شُحٌّ هَالِعٌ وَجُبْنٌ خَالِعٌ " .
صحيح (الألباني) حكم

ﻋﺰ ﻭﺟﻞ រមែងតែនៅខាងបណ្ដាអ្នកត្រឹមត្រូវជានិច្ច ។

បើអល់ឡោះហ្ ﻋﺰ ﻭﺟﻞ នៅខាងអ្នក តើមានអ្វីធ្វើឲ្យអ្នកខ្លាច ?

## មេរៀនទី ៧

# មេត្តាធម៌និងករុណា

មេត្តាធម៌គឺមានសមានចិត្តនិងមានចិត្តល្អប្រពៃ ។

យើងថាអល់ឡោះហ្វ៍ﷻទ្រង់មានព្រះមេត្តាធម៌ បានសេចក្តីថាព្រះអង្គﷻចិត្តល្អបំផុត ព្រះអង្គﷻជួយយើងរាល់ពេលដែលយើងត្រូវការជំនួយ ។ យើងត្រូវជួយជានិច្ចអ្នកណាដែលសូមជំនួយ ។ បើគេធ្វើអាក្រក់មកលើយើង យើងត្រូវអត់ឱនឲ្យអ្នកនោះ ត្រូវធ្វើល្អចំពោះអ្នកនោះ ។ នេះឯងដែលគេហៅថាមានមេត្តាធម៌ ។

ជួយមនុស្សដែលសូមជំនួយជាប្រការល្អ តែប្រសើរលើសនោះទៀតគឺជួយមនុស្សដែលរងការលំបាកដោយមិនបាច់ចាំឲ្យគេសូមជំនួយ ។ មនុស្សខ្លះមានសេចក្តីថ្លៃថ្នូរ ឬមានសេចក្តីគោរពខ្លួនឯង ។ ពេលប្រទះបញ្ហា មនុស្សនោះមិនប្រាប់គេទេព្រោះមិនចង់ឲ្យគេអាណិតខ្លួន ។ ខ្លួនអ្នកទេដែលត្រូវបើកភ្នែក សម្គាល់មើលបណ្តាអ្នកដែលត្រូវការជំនួយ ។ បើអ្នកអាចជួយបាន អ្នកត្រូវតែជួយ ។ ពុំនោះទេចូរសាករកអ្នកណាដែលអាចជួយអ្នកនោះបាន ។

ករុណាបានសេចក្តីថាមានចត្តិល្អចំពោះអ្នកដទៃដែរ ។

បើគេធ្វើអ្វីដែលអ្នកមិនពេញចិត្ត អ្នកមិនត្រូវមួម៉ៅទេ មិនត្រូវស្រែកគំហកទេ តែអ្នកត្រូវរក្សាសេចក្តីគួរសម ចូរពន្យល់ឲ្យអ្នកនោះយល់ថាខ្លួនបានធ្វើអ្វីខុស ។

តើអ្នកត្រូវប្រព្រឹត្តខ្លួនដូចម្តេចនៅក្នុងករណីដូចតទៅគឺ៖

១. អ្នកកំពុងលេងជាមួយមិត្តអ្នក មិត្តអ្នកម្នាក់ដួល រងរបួស ។ មិត្តទាំងអស់របស់អ្នកសើច ។

២. អ្នកកំពុងលេង មានម្នាក់ដែលអ្នកមិនស្គាល់ដួល រងរបួស ។ មិត្តទាំងអស់របស់អ្នកសើច ។

៣. អ្នកកំពុងដើរទៅសាលារៀន ឃើញសត្វមួយបាក់ស្លាប ។ តើអ្នកត្រូវធ្វើអ្វី ?

៤. អ្នកឃើញក្មេងតូចម្នាក់ត្រូវពួកក្មេងឯទៀតវាយ តើអ្នកគួរមានប្រតិកម្មយ៉ាងណា ?

**មេរៀនទី ៨**

# ការប្រព្រឹត្តខ្លួននៅចំពោះមុខសាធារណៈជន

នេះគឺអាប្បកិរិយាដែលអ្នកត្រូវមាននៅចំពោះមុខអ្នកដទៃ ជាពិសេសពេលអ្នកនៅជាក្រុមឬក្នុងអង្គប្រជុំ ។ ពេលអ្នកនៅជុំជាមួយអ្នកដទៃ អ្នកមិនត្រូវធ្វើអាកប្បកិរិយាមិនគប្បីជាដាច់ខាត ព្រោះអ្នកនឹងធ្វើឲ្យអ្នកដទៃចាំជាប់ក្នុងចិត្តជានិច្ចថាអ្នកជាមនុស្សមិនល្អ ។ ដោយធ្វើឲ្យគេឃើញថាអ្នកមិនមានអាកប្បកិរិយាល្អប្រពៃទេនោះ គេនឹងមិនគោរពអ្នកទេ ។

មិនត្រូវប្រព្រឹត្តខ្លួនអាក្រក់នៅឯផ្ទះទេ តែមិនត្រូវប្រព្រឹត្តខ្លួនអាក្រក់នៅចំពោះមុខអ្នកដទៃទេដែរ ព្រោះអ្នកមិនត្រឹមតែធ្វើឲ្យខូចឈ្មោះខ្លួនឯងផ្ទាល់ទេ ថែមទាំងធ្វើឲ្យខូចឈ្មោះឪពុកម្តាយនិងគ្រូអ្នកដែរ ។

អាកប្បកិរិយាអ្នកនៅចំពោះមុខអ្នកដទៃ បើកឲ្យគេស្គាល់បុគ្គលលក្ខណៈរបស់អ្នក ។ ដោយបែងចែកចំណីអាហារអ្នកជាមួយអ្នកដទៃ អ្នកបង្ហាញឲ្យឃើញថាអ្នកមិនគិតតែខ្លួនឯងទេ បើអ្នកនិយាយនិងសើចលេងជាមួយអ្នកដទៃ អ្នកសម្តែងឲ្យគេឃើញថាអ្នកមិនប្រកាន់ខ្លួនទេ ។

តើអ្នកត្រូវប្រព្រឹត្តខ្លួនដូចម្តេចនៅក្នុងករណីដូចតទៅគឺៈ

១. អ្នកបានទទួលការអញ្ជើញទៅធ្វើបុណ្យខួបកំណើតមិត្តម្នាក់ ។ ពេលបរិភោគអ្នកទាំងអស់គ្នាអង្គុយឯតុដើម្បីទទួលទានបាយ តែមិត្តអ្នកម្នាក់នៅតែឯងគេមិនបានហៅគាត់ឲ្យចូលរួមបរិភោគទេ ។

២. អ្នកបានទៅដើរលេងជាមួយមិត្តអ្នក ពួកគេនិយាយអាក្រក់អំពីបុគ្គលម្នាក់ដែលអ្នកមិនចូលចិត្តដែរ ។

៣. ឪពុកអ្នកបានជូនអ្នកមកម៉ាស់យ៊ិដ្ឋ ដោយប្រាប់អ្នកថាលោកមានធុរកិច្ចលោកនឹងមកយកអ្នកទៅផ្ទះវិញពេលរួចធុរកិច្ច ។ ពេលលោកបានចេញផុត អ្នកឃើញមិត្តអ្នកទៅក្រោយម៉ាស់យ៊ិដ្ឋដើម្បីលេង ។

៤. កំពុងបម្រើការក្នុងម៉ាស់យ៊ិដ្ឋ អ្នកស្ម័គ្រចិត្តបម្រើការមុនអ្នកហៅអ្នកថា "អាភ្លើ" ។ តើអ្នកមានប្រតិកម្មដូចម្តេច ?

៥. អ្នកនៅឯសាលារៀន គ្រូមិនទាន់មកដល់ ។ មិត្តអ្នកចោលដីសលេង ។ តើអ្នកធ្វើអ្វី ?

**មេរៀនទី ៩**

# បដិសណ្ឋារកិច្ច

បដិសណ្ឋារកិច្ច (គឺការទទួលរាក់ទាក់) គឺសេចក្ដីគួរសមនិងសេចក្ដីគោរព ចំពោះបណ្ដាអ្នកដែលមកផ្ទះអ្នក ។

តើត្រូវគួរសមដូចម្ដេច ?

ការគួរសមមានច្រើនបែប ដូចជាៈ

ក) បើភ្ញៀវជាមុស្លីម អ្នកអាចចាប់ផ្ដើមដោយថា អាស់-សាឡាមូ អាឡៃគុម ។

ខ) អ្នកអាចនិយាយដោយសម្លេងតិចប្រសើរជាងស្រែក ។

គ) អ្នកអាចដាក់ទឹកឲ្យភ្ញៀវទទួលទាន ។

ឃ) អ្នកអាចនិយាយលេងជាមួយភ្ញៀវជាធម្មតា មិនបណ្ដោយឲ្យភ្ញៀវនៅតែឯងនៅកន្លែងចម្លែក ។

ហេតុអ្វីយើងត្រូវគួរសមចំពោះភ្ញៀវ ?

មូលហេតុដែលយើងត្រូវសម្ដែងការគួរសមចំពោះភ្ញៀវ គឺដើម្បីនឹងឲ្យភ្ញៀវរីករាយ ។ អល់ឡោះហ៍ﷻនឹងពេញចិត្តយើង យើងនឹងបានរង្វាន់ (សូវ៉ាប់) ។ ឪពុកម្ដាយយើងនឹងពេញចិត្តយើងដែរ ។

បើអ្នកគួរសមចំពោះភ្ញៀវនិងអ្នកដទៃ គេនឹងគោរពអ្នកតបវិញ ។

តើអ្នកត្រូវប្រព្រឹត្តខ្លួនដូចម្ដេច ពេលៈ

១. គេមកផ្ទះអ្នកពេលដែលអ្នកនឿយហត់និងត្រូវការដេក ?

២. មិត្តអ្នកមកលេងអ្នកពេលស្វ៍ឡាត់ម៉ាក់រិប ?

៣. ដល់ពេលបាយ អ្នកមានភ្ញៀវ ?

៤. ញាតិអ្នកលេងជាមួយអ្នក ធ្វើឲ្យរបស់លេងអ្នកខូច ?

៥. អ្នកមិនដឹងទេថាអ្នកដែលខ្វះការទទួលរាក់ទាក់នោះ នឹងមានប្រតិកម្មយ៉ាងណា ?

## មេរៀនទី ១០

# ជួយបណ្ដាអ្នកទន់ខ្សោយ

ជួយអ្នកទន់ខ្សោយ មិនត្រឹមតែជួយបណ្ដាអ្នកដែលមិនខ្លាំង មិនរឹងមាំប៉ុណ្ណោះទេ តែជួយបណ្ដាអ្នកដែលមានបញ្ហាចវិកាឬបញ្ហាសុខភាពនិងបណ្ដាអ្នកដែលខ្វះខាតដែរ ។

អ្នកខ្វះខាតគឺអ្នកដែលត្រូវការជំនួយ ។ អល់ឡោះហ្ម៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអានថាអ្នកមានទ្រព្យត្រូវបរិច្ចាគមួយប៉ែកតូចឲ្យទៅអ្នកខ្វះខាត ។

ពេលយើងជួយអ្នកដែលមិនសូវសម្បូរទ្រព្យដូចយើងដែរនោះ យើងត្រូវអរព្រះគុណអល់ឡោះហ្ម៍ﷻផង ដែលមានព្រះគុណដល់យើងដោយឲ្យយើងផុតពីការខ្វះខាត ។

ព្រោះតែអល់ឡោះហ្ម៍ﷻប្រទានឲ្យយើងច្រើន យើងត្រូវចំណាយទ្រព្យនោះដើម្បីជួយអ្នកដទៃ ធ្វើដូច្នេះដើម្បីប្រើទ្រព្យយើងឲ្យត្រឹមត្រូវនិងស្របតាមគន្លងធម៌ មិនមែនចាយវាយទៅលើរបស់ថ្លៃឬឥតប្រយោជន៍តែម្យ៉ាងនោះទេ ។

ចូរគិតដល់សេចក្ដីទន់ខ្សោយរបស់យើង អល់ឡោះហ្ម៍ﷻបានជួយយើង ។ យើងត្រូវសាកជួយវិញដែរជនក្រីក្រ ជនរងរបួស បណ្ដាអ្នកដែលមិនមានដូចយើងនោះ ។

យើងមិនចាំបាច់មានទ្រព្យនិងមានអំណាចទេដើម្បីជួយអ្នកដទៃនោះ ។ បើមានពេលទំនេរ យើងអាចទៅមើលជនចាស់ជរាឬអ្នកជម្ងឺនៅឯមន្ទីរពេទ្យបាន ។ អ្វីដែលយើងត្រូវធ្វើគឺនិយាយសំណេះសំណាលជាមួយពួកគាត់ ដើម្បីកំដរពួកគាត់ កុំឲ្យពួកគាត់មានអារម្មណ៍កណ្ដោចកណ្ដែង ឬដើម្បីធ្វើឲ្យពួកគាត់រីករាយឡើង ។ យើងអាចជួយជនចាស់ជរានៅជុំវិញខ្លួនយើងបាន ដោយទៅទិញអីវ៉ាន់ឲ្យគាត់ឬជួយគាត់ធ្វើចម្ការ ដាំដំណាំ ។

ជួយអ្នកដទៃ អល់ឡោះហ្ម៍ﷻនឹងជួយយើងក្នុងថ្ងៃជំនុំជម្រះ ។

## មេរៀនទី ១១

# សប្បុរសធម៌

មានសប្បុរសធម៌មានន័យថាមានចិត្តល្អប្រពៃនិងប្រកបដោយមិត្តភាព ។ គឺយកចិត្តទុកដាក់នឹងរបស់ឬមនុស្ស ។ ត្រូវមានសប្បុរសធម៌ជានិច្ចចំពោះអ្នកដទៃ និងជួយអ្នកដទៃ ។ អល់ឡោះហ៊ូ ﷻ មានព្រះសប្បុរសធម៌ដាច់គេ បានសេចក្ដីថាព្រះអង្គ ﷻ មានចិត្តល្អប្រពៃចំពោះយើង ព្រះអង្គ ﷻ នៅខាងយើងជានិច្ចពេលយើងត្រូវការព្រះអង្គ ﷻ ។

អល់ឡោះហ៊ូ ﷻ មានចិត្តល្អប្រពៃណាស់ចំពោះយើង យើងត្រូវមានចិត្តល្អប្រពៃណាស់ដែរចំពោះអ្នកដទៃ ។ កាលណាអ្នកចិត្តល្អចំពោះអ្នកដទៃ អ្នកដទៃក៏ចិត្តល្អចំពោះអ្នកដែរ ។ ដូចគ្នាដែរ កាលណាអ្នកចិត្តអាក្រក់ដាក់អ្នកដទៃ អ្នកដទៃនឹងចិត្តអាក្រក់ដាក់អ្នក ។

ធ្វើល្អចំពោះអ្នកដទៃមិនមែនជាការងាយស្រួលរហូតទេ ជាពិសេសពេលគេមានចិត្តអាក្រក់ចំពោះអ្នក ។ បើអ្នកនៅតែមានចិត្តសប្បុរសនិងស្លូតត្រង់ ទោះបីគេធ្វើអាក្រក់ដាក់អ្នកក៏ដោយ អ្នកនឹងបានបុណ្យ (ស្វាវ៉ាប់) មនុស្សនឹងស្រឡាញ់អ្នក អ្នកនឹងទទួលបានប្រិយភាពនិងមិត្តភាពពីមនុស្ស ។

សប្បុរសធម៌រមែងសងវិញជាមិនខាន ព្រោះធ្វើល្អចំពោះអ្នកដទៃ ថ្ងៃណាមួយពេលអ្នកជួបប្រទះបញ្ហា គេនឹងនឹកឃើញអ្នកហើយនឹងថា៖ "គាត់បានជួយខ្ញុំកាលខ្ញុំត្រូវការជំនួយ ។ ពេលនេះដល់វេនខ្ញុំជួយគាត់វិញ ។"

អល់ឡោះហ៊ូ ﷻ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ អាយ៉ាស់ ១៣ (៥:១៣) ថា៖

فَٱعْفُ عَنْهُمْ وَٱصْفَحْۚ إِنَّ ٱللَّهَ يُحِبُّ ٱلْمُحْسِنِينَ ﴿١٣﴾

*១៣. ...ចូរអ្នកអត់ទោសឲ្យពួកគេនិងបំភ្លេចចោលទៅ[នូវកំហុសពួកគេ] ការពិតអល់ឡោះហ៍ទ្រង់សព្វព្រះហឫទ័យបណ្ដាអ្នកប្រព្រឹត្តិល្អ[ចំពោះជនដទៃ] ។*

## មេរៀនទី ១២

# ចណ្ឌភាព ឬ អាការកាចសាហាវ

ចណ្ឌភាពគឺសេចក្ដីកាចសាហាវ យង់ឃ្នង ។

ចិត្តប្រកបដោយចណ្ឌភាព គឺអាការកាច អាការគ្មានមេត្តាករុណា ។ កាចសាហាវជាប្រការអាក្រក់ណាស់ ផ្ទុយពីមេត្តាធម៌ ។

ឧទាហរណ៍ បើអ្នកណាមួយជួបប្រទះប្រការអាក្រក់ អ្នកគប្បីជួយអ្នកនោះ តែអ្នកបែរជាសើចឲ្យអ្នកនោះវិញ ដូច្នេះអ្នកសម្ដែងឲ្យឃើញនូវចណ្ឌភាព ពោលគឺអ្នកកាចសាហាវ គ្មានមេត្តាករុណា ។

សាសនាអ៊ីស្លាមជារបៀបរស់នៅដែលមានមេត្តាធម៌ជាមូលដ្ឋាន ប្រឆាំងនឹងចណ្ឌភាព ពោលគឺ ជំទាស់សេចក្ដីកាចសាហាវយង់ឃ្នងទាំងស្រុង ។

កាលពីសម័យព្រះសាស្ដាមូហាំម៉ាដ់យើងﷺ គេចងពួកអ្នកទោសសង្គ្រាមប្រុសក្ដីស្រីក្ដី ។ ពេលព្រះសាស្ដាﷺត្រឡប់មកពីសមរភូមិវិញ ឃើញដូច្នេះព្រះអង្គﷺក្រោធ ។ ព្រះអង្គﷺបញ្ជាឲ្យគេស្រាយចំណងឈ្លើយសឹកភ្លាម ឲ្យគេដាក់បាយទឹកឲ្យពួកគេបរិភោគ ។ ព្រះអង្គﷺមានព្រះវចនៈថាត្រូវឲ្យជម្រកស្ត្រីនិងកូនក្មេង ត្រូវថែរក្សាពួកគេ ។ ពេលឃើញថាព្រះសាស្ដាមូហាំម៉ាដ់ﷺមានធម៌មេត្តា មានករុណាប្រណី ពួកឈ្លើយសង្គ្រាមក៏បានទៅជាមូស្លីម ។

សឲ្យឃើញថាមធ្យោបាយតែមួយគត់ សម្រាប់បង្ហាញនូវសោភ័ណភាពរបស់សាសនាអ៊ីស្លាមដល់បណ្ដាអ្នកមិនមែនមូស្លីម គឺបង្ហាញពួកគេឲ្យឃើញនូវអ្វីៗដែលសាសនាអ៊ីស្លាមបានបង្ហាត់បង្រៀនយើង ។ ចូរកុំកាចសាហាវជាដាច់ខាត ចូរប្រព្រឹត្តខ្លួនយ៉ាងត្រឹមត្រូវជានិច្ច ។

## មេរៀនទី ១៣

# សេចក្ដីទៀងត្រង់

សេចក្ដីទៀងត្រង់ត្រូវនឹងសច្ចៈនិងសេចក្ដីស្មោះ ។

ពាក្យស្លោកថា៖ "សេចក្ដីទៀងត្រង់ជាគោលនយោបាយប្រសើរបំផុត" មានន័យថាអ្វី ? មានន័យថាបើអ្នកត្រង់ ជីវិតអ្នកនឹងមិនត្រឹមតែប្រសើរទេ តែអ្នកនឹងនៅក្នុងចំណោមបណ្ដាអ្នកដែលអល់ឡោះហ្ទ៍ ﷻ ស្រឡាញ់ដែរ ។

បើអ្នកមិនត្រង់ទេ អ្នកត្រូវតែចងចាំរឿងទាំងអស់ដែលអ្នកបាននិយាយកុហកដើម្បីបិទបាំងរឿងកុហកទាំងនេះកុំឲ្យគេដឹង អ្នកត្រូវតែនិយាយកុហកតទៅទៀតទាល់តែវាក្លាយទៅជាទម្លាប់ ។

ព្រះគម្ពីរគួរអានថែងអំពីសារសំខាន់របស់សេចក្ដីពិតនៅក្នុងស៊ូរ៉ោះតុ៍ អាត់-តៅបាស៊ុ (៩:១១៩) ថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ ٱتَّقُواْ ٱللَّهَ وَكُونُواْ مَعَ ٱلصَّٰدِقِينَ ﴿١١٩﴾

*១១៩. បណ្ដាអ្នកមានសទ្ធាអើយ ចូរកោតខ្លាចអល់ឡោះហ្ទ៍[យ៉ាងស៊ប់ចិត្ត] ចូរពួកអ្នកនៅជាមួយបណ្ដាសច្ចការី ។*

ស៊ូរ៉ោះតុ៍ អាល់-បាក៏ារ៉ោះតុ៍ អាយ៉ាស៊ុ ១៧៧ ថែងអំពីគុណសម្បត្តិរបស់បណ្ដាអ្នកមានសទ្ធាស៊ប់ចិត្ត បុគ្គលទាំងនោះប្រកបដោយសេចក្ដីស្មោះ ។

۞لَّيْسَ ٱلْبِرَّ أَن تُوَلُّواْ وُجُوهَكُمْ قِبَلَ ٱلْمَشْرِقِ وَٱلْمَغْرِبِ وَلَٰكِنَّ ٱلْبِرَّ مَنْ ءَامَنَ بِٱللَّهِ وَٱلْيَوْمِ ٱلْأٓخِرِ وَٱلْمَلَٰٓئِكَةِ وَٱلْكِتَٰبِ وَٱلنَّبِيِّۦنَ وَءَاتَى ٱلْمَالَ عَلَىٰ حُبِّهِۦ ذَوِى ٱلْقُرْبَىٰ وَٱلْيَتَٰمَىٰ وَٱلْمَسَٰكِينَ وَٱبْنَ ٱلسَّبِيلِ وَٱلسَّآئِلِينَ وَفِى ٱلرِّقَابِ وَأَقَامَ ٱلصَّلَوٰةَ وَءَاتَى ٱلزَّكَوٰةَ وَٱلْمُوفُونَ بِعَهْدِهِمْ إِذَا عَٰهَدُواْ ۖ وَٱلصَّٰبِرِينَ فِى ٱلْبَأْسَآءِ وَٱلضَّرَّآءِ وَحِينَ ٱلْبَأْسِ ۗ أُوْلَٰٓئِكَ ٱلَّذِينَ صَدَقُواْ ۖ وَأُوْلَٰٓئِكَ هُمُ ٱلْمُتَّقُونَ ﴿١٧٧﴾

*១៧៧. មិនត្រឹមត្រូវទេ ដែលពួកអ្នកបែរមុខទៅទិសខាងកើតនិងទិសខាងលិចនោះ តែត្រឹមត្រូវគឺបុគ្គលដែលមានសទ្ធាចំពោះអល់ឡោះហ្ទ៍ ចំពោះថ្ងៃអវសាន ចំពោះអស់ទេវតា ចំពោះគម្ពីរ ចំពោះអស់សាស្ដា[របស់អល់ឡោះហ្ទ៍] ដែលបរិច្ចាគទ្រព្យដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្ទ៍ឲ្យ ទៅបណ្ដាញាតិជិតស្និទ្ធ បណ្ដាកូនកំព្រា*

*បណ្ដាអ្នកក្រីក្រ បណ្ដាអ្នកដំណើរ[ខ្សត់ទ្រព្យ] បណ្ដាអ្នកសូមទាននិងដើម្បីដោះលែងមនុស្សក្រោមនឹមគេ ដែលធ្វើនមស្ការ[បូជាអល់ឡោះហ្ទ៍] ដែលបរិច្ចាគស្ការាត់ និងបុគ្គលដែលគោរពពាក្យសន្យាពេលបានធ្វើកិច្ចសន្យា ដែលមានការអត់ធ្មត់ក្នុងពេលមានឧបសគ្គ ក្នុងពេលមានទុក្ខវេទនា ក្នុងពេលមានភយន្តរាយ ។ នូវជនទាំងនេះជាអ្នកមានសច្ចៈ ជាសទ្ធាធិមុត្ត (គឺអ្នកជឿអល់ឡោះហ្ទ៍ស៊ប់ចិត្ត) ។*

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលនៅក្នុងស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ អាយ៉ាស់ ១១៩ ថាៈ

قَالَ ٱللَّهُ هَٰذَا يَوۡمُ يَنفَعُ ٱلصَّٰدِقِينَ صِدۡقُهُمۡۚ لَهُمۡ جَنَّٰتٞ تَجۡرِي مِن تَحۡتِهَا ٱلۡأَنۡهَٰرُ خَٰلِدِينَ فِيهَآ أَبَدٗاۖ رَّضِيَ ٱللَّهُ عَنۡهُمۡ وَرَضُواْ عَنۡهُۚ ذَٰلِكَ ٱلۡفَوۡزُ ٱلۡعَظِيمُ ١١٩

*១១៩. [នាថ្ងៃជំនុំជម្រះ] អល់ឡោះហ្ទ៍នឹងមានតម្រាស់[ចំពោះបណ្ដាអ្នកមានសទ្ធា] ថាៈ "នេះគឺថ្ងៃដែលបណ្ដាអ្នកទៀងត្រង់[និងសុចរិត] នឹងបានទទួលផលប្រយោជន៍ពីសេចក្ដីទៀងត្រង់របស់ខ្លួន ។ ពួកគេនឹងបានទទួលសួនឧទ្យានដែលមានស្ទឹងហូរនៅខាងក្រោម ពួកគេនឹងស្ថិតនៅទីនោះជានិច្ចអនន្ត ។ អល់ឡោះហ្ទ៍សព្វព្រះហឫទ័យពួកគេ ឯពួកគេក៏ស្រឡាញ់ព្រះអង្គដែរ ។ នេះជាជោគជ័យធំបំផុត ។"*

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលថាថ្ងៃគ្ីយ៉ាម៉ាត់ "បណ្ដាអ្នកទៀងត្រង់នឹងបានទទួលផលប្រយោជន៍ពីសេចក្ដីទៀងត្រង់របស់ខ្លួន" អល់ឡោះហ្ទ៍ﷻនឹងឲ្យពួកគេបាន "ចូលឋានសួគ៌" ។

## មេរៀនទី ១៤

# សេចក្តីព្រហើន

ព្រហើនគឺនិយាយស្តីបែបប្រមាថគេឬធ្វើឲ្យគេរំខានចិត្ត ។ គឺមិនគួរសម មិនមានសេចក្តីគោរពចំពោះអ្នកដទៃ ។



ព្រហើនជាទម្លាប់អាក្រក់ ។ វាអាចធ្វើឲ្យអ្នកបាត់បង់មិត្តភក្តិបាន អាចធ្វើឲ្យមនុស្សស្អប់អ្នកបាន ។ ជួនកាលគេអាចប្រហើនដោយមិនដឹងខ្លួន ។ ឧទាហរណ៍៖

១. តមាត់ឪពុកម្តាយ ។

២. មិនស្តាប់គេកំពុងនិយាយជាមួយខ្លួន ។

៣. ជេរឬនិយាយពាក្យមិនពីរោះស្តាប់ ទោះបីអ្នកក្រោធក៏ដោយ ។

៤. និយាយតវ៉ាពេលឪពុកម្តាយអ្នកឲ្យធ្វើអ្វីមួយ ។

៥. និយាយកំប្លែងចំអាសចំអូង/មិនពីរោះស្តាប់ ។

អ្នកមិនត្រូវព្រហើនជាដាច់ខាតចំពោះអ្នកដទៃ ពុំនោះទេគេនឹងមិនគោរពអ្នកទេ ។

ពាក្យស្លោកថា៖ "បើអ្នកមិនអាចនិយាយល្អបានទេ ចូរចៀសវាងនិយាយ ។"

## មេរៀនទី ១៥

# សេចក្ដីខ្ជិលច្រអូស

ខ្ជិលច្រអូសគឺចៀសវាងធ្វើកិច្ចការ ឬមិនខំប្រឹងប្រែងដើម្បីនឹងបានសម្រេចកិច្ចការនីមួយ ។

សេចក្ដីខ្ជិលច្រអូសជាទម្លាប់អាក្រក់ ព្រោះអ្នកខ្ជះខ្ជាយពេលវេលា ពេលវេលាមានតម្លៃបំផុត ។

អល់ឡោះហ្ជ៏ﷻឲ្យអ្នករស់នៅលើផែនដីនេះ ដោយមានកំណត់ពេល បើអ្នកខ្ជះខ្ជាយពេលវេលា អ្នកសម្ដែងឲ្យឃើញថាអ្នកមិនដឹងព្រះគុណអល់ឡោះហ្ជ៏ﷻ ។

មនុស្សនៅស្ងៀមមិនដំណើរការជាមិត្តសម្លាញ់របស់ស្ហៃតូនﷺ ។ ការនៅស្ងៀមមិនដំណើរការបានសេចក្ដីថាមិនធ្វើអ្វីសោះ ពេលអ្នកមិនធ្វើអ្វីសោះ បានតែបំផ្លាញពេលវេលានោះ ស្ហៃតូនﷺនឹងដឹកនាំចិត្តអ្នក វាﷺនឹងបញ្ឆោះអ្នកឲ្យធ្វើអ្វីដែលអ្នកធ្លាប់តែចៀងវាងធ្វើ ។

បើអ្នកនឿយហត់ អ្នកសម្រាកយកកម្លាំង មិនបានសេចក្ដីថាអ្នកខ្ជិលច្រអូសទេ ។ អ្នកមិនខុសទេ ។ តែបើអ្នកអង្គុយមួយកន្លែងពេញមួយថ្ងៃ មិនធ្វើកិច្ចការសោះ ឬបានតែមើលទូរទស្សន៍ ឬលុះយប់ជ្រៅទើបដេកដោយគ្មានមូលហេតុ ធ្វើបែបនេះគេហៅខ្ជិលច្រអូស ។



អ្នកមិនត្រូវថាអ្នកអផ្សុក ជាដាច់ខាត ។ មានតែពួកឥតគំនិតទេដែលនិយាយបែបនេះ ។ បើអ្នកធ្វើកិច្ចការណាមួយស្រេចហើយ ចូរអានសៀវភៅ ។ អ្នកមិនត្រូវអានតែអ្វីដែលទាក់ទងតែនឹងការសិក្សារបស់អ្នកមួយមុខទេ អ្នកអាចអានសៀវភៅរឿងគួរឲ្យចាប់អារម្មណ៍ផ្សេងៗ ដែលអាចធ្វើឲ្យគំនិតអ្នករីកចម្រើនបាន ។ ចូររកអ្វីដែលផ្ដល់ផលប្រយោជន៍ឬគ្រឿងកំសាន្តអារម្មណ៍ ដើម្បីនឹងកុំឲ្យអ្នកនៅទំនេរ ។ ចូរអានគួរអានឬសាកអនុវត្តិឬសិក្សាអ្វីមួយថ្មីដែលទាក់ទាញចិត្ត ។

ចូរអ្នកគិតមើលពិភពលោកទាំងមូលដែលគួរឃើញ តើគេអាចថាអផ្សុកបាន

ដូចម្ដេច ? មិនអាចទេ !!!

គេបណ្ដោះនិស្ស័យមុស្លីមឲ្យមានចលនាជានិច្ច មិនឲ្យចេះអផ្សុកទេ ព្រោះមុស្លីមត្រូវប្រកបកិច្ចការដើម្បីជីវិតពីរ ។ មនុស្សភាគច្រើនធ្វើការដើម្បីបង្គ្រប់កិច្ចប៉ុណ្ណោះ មិនលើសពីនេះទេ ។ មុស្លីម ផ្ទុយទៅវិញ ត្រូវប្រកបកិច្ចការដើម្បីជីវិតលោកនេះនិងដើម្បីជីវិតលោកមុខ ព្រោះគេដឹងថាជីវិតមួយទៀតរង់ចាំខ្លួននៅឯនាយ ក្រោយពីបានស្លាប់ ។ យើងត្រូវធ្វើកិច្ចការដើម្បីជីវិតលោកមុខទាន់យើងនៅមានពេលអាចធ្វើបាន ដើម្បីនឹងបានផលប្រយោជន៍ក្នុងថ្ងៃជំនុំជម្រះ ។

## មេរៀនទី ១៦

# សេចក្តីតក់ក្រហល់

តក់ក្រហល់ គឺធ្វើការនីមួយប្រញាប់ពេកបណ្តាលឲ្យអ្នកមិនអាចគិតហ្មត់ចត់តាមដែលអាចគិតបាន ។ កាលណាអ្នកតក់ក្រហល់ កាលនោះអ្នកអាចធ្វើខុសបានដោយភាន់ច្រឡំ ។

បើអ្នកយកពេលធ្វើកិច្ចការនីមួយតាមដំណើរ មិនបង្ខំទេ អ្នកនឹងមានពេលគិតច្រើន ដូច្នេះអ្នកនឹងធ្វើកិច្ចការនោះបានល្អ ។ តែពេលអ្នកប្រញាប់ប្រញាល់ឲ្យតែរួច ខួរក្បាលអ្នកធ្វើការយ៉ាងលឿន បណ្តាលឲ្យអ្នកអាចភ្លេចអ្វីមួយដែលអាចធ្វើឲ្យមានបញ្ហាច្រើនពេលក្រោយ ។

ពាក្យស្លោកថាៈ "ប្រញាប់ពេកធ្វើឲ្យខាតពេល ។"

មានន័យថាបើអ្នកបន្ទាន់ការងារពេក អ្នកអាចភ្លេចភ្លាំងប្រការនីមួយដែលអាចធ្វើឲ្យអ្នកមានបញ្ហាច្រើនលើសដើម បើអ្នកមិនយកពេលវេលាធ្វើការនោះហ្មត់ចត់តាំងពីដំបូងមកទេនោះ ។

ប្រការសំខាន់មួយដែលអ្នកមិនត្រូវប្រញាប់ប្រញាល់ គឺស្ឡាតុ ។ បើអ្នកស្ឡាតុយ៉ាងលឿន បានសេចក្តីថាអ្នកមិនយកចិត្តទុកដាក់នឹងអល់ឡោះហ៍ ﷻ ទេ សឲ្យឃើញថាអ្នកមិនដឹងព្រះគុណអល់ឡោះហ៍ ﷻ ទេ ។ ប្រញាប់ប្រញាល់ក្នុងស្ឡាតុបានសេចក្តីដែរថាអ្នកបានទួលផលបុណ្យតិចពីស្ឡាតុនោះ ។



ចូរយកពេលជានិច្ច ដើម្បីធ្វើកិច្ចការ ។ ចូរគិតមុនចុះដៃធ្វើ ។ ចូរកុំយកពេលយូរពេក ដល់ថ្នាក់មិនបានដល់ទីបញ្ចប់ តែចូរកុំតក់ក្រហល់ពេកដែរ វាអាចបណ្តាលឲ្យភ្លេចភ្លាំងប្រការនីមួយដែលនឹងតម្រូវឲ្យអ្នកធ្វើសាឡើងវិញពីដំបូង ។

ប្រការសំខាន់ដែលអ្នកត្រូវប្រញាប់ប្រញាល់នោះគឺ ប្រញាប់ទៅស្ឡាតុពេលដល់ម៉ោងស្ឡាតុភ្លាម ឬប្រញាប់ទៅស្ឡាតុយ៉ាម៉ាអាុស្ ។ ពេលអ្នកឮអាស្សាន អ្នកត្រូវប្រញាប់ទៅចូលរួមស្ឡាតុ ។

អ្នកគប្បីធ្វើអ្វីប្រសិនបើ៖

១. អ្នកកំពុងតែស្ងំទ្បាត់ស្រាប់បងប្អូនអ្នកមកផ្ទះអ្នកដើម្បីលេងជាមួយអ្នក ?

២. អ្នកកំពុងតែធ្វើកិច្ចការសាលានៅក្នុងបន្ទប់ អ្នកដឹងថា ១០ នាទីទៀតទូរទស្សន៍នឹងបញ្ចាំងកីឡាប្រកួតបាល់ទាត់ ។

៣. អ្នកកំពុងតែបរិភោគបាយជាមួយគ្រួសារអ្នក មិត្តអ្នកហៅអ្នកទៅលេង ។

តើបុគ្គលតក់ក្រហល់នឹងធ្វើអ្វីក្នុងករណីខាងលើនេះ នឹងបានលទ្ធផលអ្វី ?

## មេរៀនទី ១៧

# អំនួត

អំនួតជាប៉ែកមួយនៃការសម្លែងឲ្យគេឃើញ ។

បុគ្គលអាចសម្លែងគេច្រើនបែបយ៉ាង បែបសម្លែងគេដោយចាយវាយប្រាក់ច្រើននៅចំពោះគេជាដើម តែពេលបុគ្គលសម្លែងគេដោយសម្ដីគេហៅថាអំនួត ។

ហេតុអ្វីនិយាយអួតគេជាកំហុស ?

យើងដឹងថាសម្លែងគេជាទង្វើមួយដែលធ្វើឲ្យយើងមានអារម្មណ៍ ថាគ្រាន់បើជាងគេ ។ ធ្វើបែបនេះ អ្នកដទៃមានអារម្មណ៍ថាខ្លួនតូចតាច មិនសំខាន់ ។ នេះគឺមូលហេតុបញ្ជាក់ថាអួតដាក់គេជាទង្វើអាក្រក់ ។



អល់ឡោះហ្ជ៍ﷻមិនស្រឡាញ់ អ្នកអួតដាក់គេទេ ព្រោះព្រះអង្គﷻបង្កើតយើងមកស្មើគ្នា ។ ដូច្នេះ បុគ្គលណាដែលពើងទ្រូងសម្លែងដាក់គេ គិតថាខ្លួនប្រសើរជាងអ្នកដទៃ បុគ្គលនោះប្រកាន់ខ្លួនហួសហេតុ ។

ព្រះគម្ពីរគួរអាន (៣១:១៨) ចែងថា៖

وَلَا تُصَعِّرْ خَدَّكَ لِلنَّاسِ وَلَا تَمْشِ فِي ٱلْأَرْضِ مَرَحًا ۖ إِنَّ ٱللَّهَ لَا يُحِبُّ كُلَّ مُخْتَالٍ فَخُورٍ ١٨

*១៨. ចូរកូនកុំបែរថ្ពាល់ចេញពីបណ្ដាមនុស្ស ចូរកូនកុំដើរក្រអឺតនៅលើផែនដីឡើយ ។ អល់ឡោះហ្ជ៍មិនសព្វព្រះហឫទ័យមនុស្សព្រហើន សម្បូរអំនួតគយរទេ ។*

ដែលយើងមិនត្រូវអួតដាក់គេនោះ មិនបានសេចក្ដីថាយើងមិនអាចរីករាយបាននោះទេ ។ យើងអាចរីករាយបាន អាចឲ្យមិត្តនិងគ្រួសារយើងឃើញបានថាយើងរីករាយ តែព្រោះតែយើងរីករាយ មិនមែនក្នុងបំណងអួតដាក់គេទេ ។

តើមនុស្សមានអំនួតនឹងនិយាយដូចម្ដេចអំពីព្រឹត្តិការណ៍តទៅ ប្រៀបនឹងមនុស្សដែលគេបានបង្ហាត់បង្រៀនកុំឲ្យអួតដាក់គេ ?

១. ពេលប្រឡងសិក្សាជាប់លេខមួយ ។

២. ពេលសូត្រឌូអាអ៊ំឲ្យគេស្តាប់នៅក្នុងម៉ាស់យ៉ិដ ។

៣. ពេលឈ្នះបានមេដាយក្នុងទិវាប្រកួតកីឡានៅឯសាលារៀនអ៊ីស្លាម ។

៤. ពេលឈ្នះមិត្តក្នុងការប្រកួតល្បែង (កីឡាតិន្និស កីឡាស្រ្កាបឹល ។ល ។) ។

៥. ពេលថ្លែងសុន្ទរកថានៅចំពោះមុខសាធារណៈជន ។

## មេរៀនទី ១៨

# ការសងសឹក

ការសងសឹកគឺ "វាយតតបវិញ" ទៅលើបុគ្គលដែលបានវាយប្រហារមកលើអ្នក ។ បានសេចក្ដីថាសងវិញ ។



អល់ឡោះហ្វ៍عزوجلមានព្រះបន្ទូលថា អ្នកមានសិទ្ធិសងសឹកបើអ្នកចង់ (ដោយមានលក្ខខណ្ឌស្របតាមច្បាប់ស្ហារីអ៊ាស្ស៍) តែអ្នកគប្បីលើកលែងទោស ។

មានសុភាសិតបរទេសខ្លះដែរ ដែលណែនាំអ្នកឲ្យចេះលះបង់ចោលការសងសឹក គឺ៖

ក. លើកលែងទោស លែងនឹកនា ។

ខ. កប់ចោលពូថៅសង្គ្រាម ។

ព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمមានព្រះវចនៈ ថា ប្រការជាទីគោរពដ៏ខ្ពង់ខ្ពស់មួយ គឺលើកលែងទោសឲ្យបុគ្គលណាដែលបានប្រព្រឹត្តអាក្រក់មកលើខ្លួនអ្នក ។

*Sources:*
imamia.org
shia974.fr
www.madressa.net
https://www.imamreza.net/old/eng/imamreza.php?id=3124

| | |
|---|---|
| 25 The Book of Jihad | كتاب الجهاد |
| (6)Chapter: Concession Allowing One Who Has A Mother To Stay Behind | باب الرُّخْصَةِ فِي التَّخَلُّفِ لِمَنْ لَهُ وَالِدَةٌ . |
| It was narrated from Mu'awiyah bin Jahimah As-Sulami, that Jahimah came to the Prophet (ﷺ) and said: "O Messenger of Allah! I want to go out and fight (in Jihad) and I have come to ask your advice." He said: "Do you have a mother?" He said: "Yes." He said: "Then stay with her, for Paradise is beneath her feet." | أَخْبَرَنَا عَبْدُ الْوَهَّابِ بْنُ عَبْدِ الْحَكَمِ الْوَرَّاقُ، قَالَ حَدَّثَنَا حَجَّاجٌ، عَنِ ابْنِ جُرَيْجٍ، قَالَ أَخْبَرَنِي مُحَمَّدُ بْنُ طَلْحَةَ، - وَهُوَ ابْنُ عَبْدِ اللَّهِ بْنِ عَبْدِ الرَّحْمَنِ - عَنْ أَبِيهِ، طَلْحَةَ عَنْ مُعَاوِيَةَ بْنِ جَاهِمَةَ السُّلَمِيِّ، أَنَّ جَاهِمَةَ، جَاءَ إِلَى النَّبِيِّ صلى الله عليه وسلم فَقَالَ يَا رَسُولَ اللَّهِ أَرَدْتُ أَنْ أَغْزُوَ وَقَدْ جِئْتُ أَسْتَشِيرُكَ . فَقَالَ " هَلْ لَكَ مِنْ أُمٍّ " . قَالَ نَعَمْ . قَالَ " فَالْزَمْهَا فَإِنَّ الْجَنَّةَ تَحْتَ رِجْلَيْهَا " . |
| Grade: Sahih (Darussalam)<br>Reference : Sunan an-Nasa'i 3104<br>In-book reference : Book 25, Hadith 20<br>English translation : Vol. 1, Book 25, Hadith 3106 | Source: https://sunnah.com/nasai:3104 |

| | |
|---|---|
| 2 The Book of Purification | كتاب الطهارة |
| (1)Chapter: The virtue of wudu’ | (1) باب فَضْلِ الْوُضُوءِ |
| Abu Malik at-Ash'ari reported:<br><br>The Messenger of Allah (ﷺ) said: Cleanliness is half of faith and al-Hamdu Lillah (all praise and gratitude is for Allah alone) fills the scale, and Subhan Allah (Glory be to Allah) and al-Hamdu Lillah fill up what is between the heavens and the earth, and prayer is a light, and charity is proof (of one's faith) and endurance is a brightness and the Holy Qur'an is a proof on your behalf or against you. All men go out early in the morning and sell themselves, thereby setting themselves free or destroying themselves. | حَدَّثَنَا إِسْحَاقُ بْنُ مَنْصُورٍ، حَدَّثَنَا حَبَّانُ بْنُ هِلاَلٍ، حَدَّثَنَا أَبَانٌ، حَدَّثَنَا يَحْيَى، أَنَّ زَيْدًا، حَدَّثَهُ أَنَّ أَبَا سَلاَّمٍ حَدَّثَهُ عَنْ أَبِي مَالِكٍ الأَشْعَرِيِّ، قَالَ قَالَ رَسُولُ اللَّهِ صلى الله عليه وسلم " الطُّهُورُ شَطْرُ الإِيمَانِ وَالْحَمْدُ لِلَّهِ تَمْلأُ الْمِيزَانَ . وَسُبْحَانَ اللَّهِ وَالْحَمْدُ لِلَّهِ تَمْلآنِ - أَوْ تَمْلأُ - مَا بَيْنَ السَّمَوَاتِ وَالأَرْضِ وَالصَّلاَةُ نُورٌ وَالصَّدَقَةُ بُرْهَانٌ وَالصَّبْرُ ضِيَاءٌ وَالْقُرْآنُ حُجَّةٌ لَكَ أَوْ عَلَيْكَ كُلُّ النَّاسِ يَغْدُو فَبَائِعٌ نَفْسَهُ فَمُعْتِقُهَا أَوْ مُوبِقُهَا " . |
| Reference : Sahih Muslim 223<br>In-book reference : Book 2, Hadith 1<br>USC-MSA web (English) reference : Book 2, Hadith 432<br>(deprecated numbering scheme) | https://sunnah.com/muslim:223 |

| | |
|---|---|
| 15 Jihad (Kitab Al-Jihad) | كتاب الجهاد |
| (869) Chapter: Regarding Bravery And Cowardice | (22) باب فِي الْجُرْأَةِ وَالْجُبْنِ |
| Narrated AbuHurayrah:<br>I heard the Messenger of Allah (ﷺ) say: What is evil in a man are alarming niggardliness and unrestrained cowardice. | حَدَّثَنَا عَبْدُ اللَّهِ بْنُ الْجَرَّاحِ، عَنْ عَبْدِ اللَّهِ بْنِ يَزِيدَ، عَنْ مُوسَى بْنِ عُلَىِّ بْنِ رَبَاحٍ، عَنْ أَبِيهِ، عَنْ عَبْدِ الْعَزِيزِ بْنِ مَرْوَانَ، قَالَ سَمِعْتُ أَبَا هُرَيْرَةَ، يَقُولُ سَمِعْتُ رَسُولَ اللَّهِ صلى الله عليه وسلم يَقُولُ : " شَرُّ مَا فِي رَجُلٍ شُحٌّ هَالِعٌ وَجُبْنٌ خَالِعٌ " . |
| Grade: Sahih (Al-Albani) | صحيح (الألباني) حكم |
| Reference : Sunan Abi Dawud 2511<br>In-book reference : Book 15, Hadith 35<br>English translation : Book 14, Hadith 2505 | source: https://sunnah.com/abudawud:2511 |